# ការរៀបចំផ្ទះសំរាប់ភ្លើងឆេះព្រៃ

Fact Sheet 2 – Community Risk Management. Revised 28/09/2004 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ផែនការការពារផ្ទះលោកអ្នក :   ការរៀបចំផ្ទះលោកអ្នកសំរាប់រដូវភ្លើងឆេះព្រៃ

**ប្រសិនបើលោកអ្នកធ្វើតាមគោលការណ៍ដ៏សាមញ្ញទាំងនេះ លោកអ្នកអាចបន្ថយការគំរាមគំហែងពីរងើកភ្លើងនិងភ្លើងឆេះព្រៃដែលប៉ះពាល់ដល់ផ្ទះលោកអ្នក:**

- សំអាតស្លឹកឈើពីទទឹក, ដំបូលនិងបំពង់បង្ហូរទឹកទ ជារឿយៗ ហើយនិងដាក់សំណាញ់ដែកដែលមានគុណភាពល្អការពារទទឹក ។
- ដាក់សំណាញ់ដែកដែលមានសរសៃតូចឆ្មារគ្របលើប្រហោងសំរាប់ខ្យល់ចេញចូលនៅលើដំបូល ។
- ពេលដាក់ធុងឧស្ម័ន LPG នៅជុំវិញផ្ទះលោកអ្នក, សូមធ្វើឲ្យប្រាកដថាដាក់វ៉ាល់បន្ធូរសម្ពាធបែរពីផ្ទះដើម្បីកុំឲ្យភ្លើងឆេះត្រង់ទៅរកផ្ទះនោះ ។
- ទុកដាក់គំនរឧសនៅឲ្យឆ្ងាយពីផ្ទះហើយគ្របផង ។
- សូមកាត់មែកឈើសុបទ្រុប, កាត់ស្មៅឲ្យខ្លីហើយនិងរាស់ស្លឹកឈើងាប់ដែលងាយឆេះ, មែកឈើនិងកំណាត់មែកតូចៗ ។
- សូមកុំដាក់មែកឈើ, ស្មៅដែលកាត់ហើយនោះ ។ល។ និង។ល។ នៅក្រោយផ្ទះលយចូលទៅដីរបស់សាលាសង្កាត់ ឬព្រៃ ។
- សូមធ្វើឲ្យប្រាកដថាបំពង់ទឹកនៅសួនច្បាររបស់លោកអ្នកវែងល្មមអាចទៅដល់របងជុំវិញផ្ទះ ។
- ដាំដើមឈើនិងដើមឈើសំរាប់លំអដែលមិនសូវងាយឆេះដោយសារមានជាតិប្រេងតិចតួច ។
- ប្រសិនបើលោកអ្នកមានអាងហែលទឹក, សូមដាក់សញ្ញា (Static Water Supply) នៅនឹងរបងមុខផ្ទះលោកអ្នក ។ សូមទាក់ទងនឹងក្រសួងរំលត់ភ្លើងនៅតំបន់លោកអ្នកដើម្បីរកពត៌មាន ។
- សូមគិតគូរទិញម៉ាស៊ិនបូមទឹកដែលងាយលើកចុះឡើងបានសំរាប់បូមទឹកពីអាងហែលទឹក ឬធុងទឹក ។
- ប្រសិនបើមានក្រុមរំលត់ភ្លើងសហគមន៍ ឬក្រុមខាងភ្លើង (Community Fire Unit ឬ Firewise group) នៅជិតលោកអ្នក, សូមចូលជាសមាជិក ។
- សូមធ្វើឲ្យប្រាកដថាមានក្បាលម៉ាស៊ិនទឹកនៅតាមផ្លូវសំរាប់រំលត់ភ្លើង (Fire hydrants) នៅជិតផ្ទះលោកអ្នកដែលងាយរកហើយនិងគ្មានអ្វីនៅរាំងផងដែរ ។

**ក្នុងគ្រាដែលភ្លើងឆេះព្រៃកំពុងគំរាមគំហែងផ្ទះលោកអ្នក:**

- សូមកុំចូលទៅក្នុងព្រៃប្រសិនបើផ្សែងឬភ្លើងមាននៅក្នុងតំបន់នោះ ។ សូមកុំជ្រួលច្របល់ហើយរាយការណ៍ពីភ្លើងទាំងអស់នោះទៅលេខ ០០០ ។
- សូមឆែកមើលបើមានអ្នកជិតខាងចាស់ៗត្រូវការជំនួយ ។
- ប្រសិនបើអាចធ្វើទៅបាន, សូមចុករន្ធទទឹកហើយចាក់ទឹកបំពេញផង ។
- ប្រសិនបើលោកអ្នកសម្រេចចិត្តជម្លៀសដោយខ្លួនឯងនោះ សូមធ្វើឲ្យបានមុនពេល ។
- ប្រសិនបើលោកអ្នកត្រូវបានប៉ូលីសរដ្ឋ NSW ឬបុគ្គលិកក្រសួងភាពអាសន្ន ACT បញ្ជាឲ្យជម្លៀស, លោកអ្នកត្រូវធ្វើតាម, ដូច្នេះសូមរៀបចំយកសត្វចិញ្ចឹម និងខ្ចប់របស់មានតម្លៃហើយនិងរៀបចំជាស្រេចសំរាប់ចាកចេញ ។
- ពាក់អាវដៃវែងនិងខោជើងវែង, ពាក់ស្បែកជើងដែលមិនឆេះភ្លើងហើយមាំផង ។
- បិទទ្វារនិងបង្អួចទាំងអស់, ខ្ចប់ប្រឡោះក្រោមទ្វារនឹងកន្សែងពោះគោឬភួយ ។
- ប្រសិនបើភ្លើងជិតមកដល់ផ្ទះលោកអ្នក, សូមយកបំពង់ទឹកនៅសួនច្បារនិងគ្រឿងខ្ចៅវាទៅទុកក្នុងផ្ទះ ដើម្បីកុំឲ្យវារលាយក្នុងភ្លើង, ក្រែងលោកអ្នកត្រូវការវានៅពេលក្រោយ ។
- ជួយរំលត់ភ្លើងដែលឆេះម្តុំៗកាលណាភ្លើងនោះបានឆេះហួសទៅ, សូមទុកនៅជិតដៃនូវបំពង់ទឹក, ជណ្តើរ, ប៉ែលនិងធុងទឹកដែក ។
- ទុកពិលមួយ និងវិទ្យុតូចមួយនៅក្នុងផ្ទះក្រែងលោគ្មានអគ្គិសនី ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៍រំលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក ។**

**ឬ មើលវែបសៃ: www.fire.nsw.gov.au www.rfs.nsw.gov.au or www.esa.act.gov.au**

**សូមចងចាំថា**

រៀចចំជាស្រេច

ដឹងជាមុន

កុំជ្រួលច្របល់

**ក្នុងពេលអាសន្ន សូមទូរស័ព្ទលេខ ០០០**